**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ៧១
ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ១៩៩៨
**សាលដីកា**
លេខៈ២១១
ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៩

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៩ ដោយមានសមាសភាពដូចតទៅៈ

១-ឯកឧត្តម ........... ជាប្រធាន
២-លោក ............. ជាចៅក្រម
៣-លោក ...............ជាចៅក្រមរបាយការណ៍
៤-លោក ............ ជាចៅក្រម
៥-លោក ............ ជាចៅក្រម
៦-លោក ............. ជាចៅក្រម
៧-លោក ............... ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក ............. ជាចៅក្រម

**ក្រឡាបញ្ជី**

-លោក .................

**តំណាងមហាអយ្យការ**

-លោក ................ ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខពីសាលដីកាលេខ៦៤ ចុះថ្ងៃទី២៣ខែ កុម្ភៈឆ្នាំ ១៩៩៨ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៩០ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះឯក សូផល លី អួង ជ្រិន អ៊ូ ទេព សាម៉ុន, គី ស៊ីង នៅ ខៀន សៀង ជឿន ប៊ុន ជឿន ស៊ីម ហួរ, នួន ដារ៉ា, អ៊ីង សួងអ៊ុយ និង ញ៉េត សុផាន់ ជាប្រជាជនក្នុងសង្កាត់ក៏ពេញ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ។

បានផ្ទេរសិទ្ធិឱ្យឈ្មោះលី អួង

និងចុងបណ្តឹងសាទុក្ខឈ្មោះមាស ហាន់ ភេទប្រុស អាយុ ៤៦ ឆ្នាំ ជាតិខ្មែរ របររកស៊ី អភិបាលខណ្ឌ ក្រុងព្រះសីហនុ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២ លេខ៤៧ ចុះថ្ងៃទី២៤ ខែកម្ភៈ ឆ្នាំ១៩៩៨ របស់លោកលី អួង ប្តឹងមិនសុខចិត្តពីសាលដីការដ្ឋប្បវេណីលេខ២៦៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៨របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៧១ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ១៩៩៩ រសប់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១៥-១២-៩៣ ដើមចោទទាំង១២នាក់ បានអះអាងថាពួកខ្លួនប្តឹងទាមទារដីទំហំ១០៥-៣៥០ម² ពីលោកមាស ហាន់ អភិបាលខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ដោយអាងហេតុថា ពួកខ្លួនបានគ្រប់គ្រងនិងថែរក្សាដីនេះ ជាច្រើនឆ្នាំមកហើយ។ នៅថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ពួកខ្លួនបានដាក់ពាក្យសុំកាន់កាប់ និងប្រើប្រាស់ដីនេះហើយ រដ្ឋអំណាចបានចេញបង្កាន់ដៃឱ្យ ពួកខ្លួនទៀតផង ។ ក្រោយមកលោក អភិបាលខណ្ឌស្ទឹងហាវ បានហាមឃាត់ខ្លួនមិនឱ្យធ្វើអាជីវកម្មលើដី នេះដោយអាងថា ដីនេះជាដីទុកបំរុងរបស់រដ្ឋ ។ ក្នុងរឿងនេះ ពួកខ្លះននៅតែប្តឹងសុំទាមទារដីនេះយកមក ធ្វើជាកម្មសិទ្ធិខ្លះវិញដដែល ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៤៥ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៩៤ របស់តុលាការក្រុងព្រះសីហនុ សម្រេចចំពោះមុខដើមចោទឈ្មោះឯក សូផល លី អួង ជ្រិន អ៊ី, នៅ ខឿន គី ស៊ីង ញ៉ែត សូផាន់ និងចុងចម្លើយឈ្មោះមាស ហាន់ កំបាំងមុខដើមចោទឈ្មោះទេព សាម៉ុន សៀង ធឿន ស៊ឹម ហូរ នួន ដាវ៉ា និងអ៊ុង សួងអ៊ុយ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលពាក្យបណ្តឹង ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៩៣ របស់ដើមចោទ ទុកជាត្រឹមត្រូវតាម ទម្រង់ច្បាប់ តែបដិសេធចោលដោយជួយពីគតិច្បាប់ ។

២- ទទួលស្គាល់ដីទំហំ១១៤-៣៣២ម² ដែលស្ថិតនៅក្នុងសង្កាត់កំពេញ ខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ ជាដីបំរុងទុករបស់រដ្ឋ ។

៣- ប្រគល់ដីទំហំ១១៤-៣៣២ម² ខាងលើនេះជូនអភិបាលខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ គ្រប់គ្រង និងប្រើប្រាស់ជាប្រយោជន៍សាធារណៈ ចាប់ពីថ្ងៃនេះតទៅ ។

៤- ប្រជាពលរដ្ឋទាំងឡាយណា ដែលបានកាន់កាប់ និងប្រើប្រាស់ប៉ះពាល់ដី ខាងលើនេះ ត្រូវរុះរើសំណង់ និងសំភារៈចេញជាបន្ទាន់ចាប់តាំងពីថ្ងៃនេះតទៅ ។

៥- ឱ្យដើមចោទបង់ប្រាក់ប្រដាប់ក្តីគឺ ពន្ធចុះបញ្ជី និងពន្ធហ្នឹង១៨០០៛ រង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់២០០៛ រង្វាន់អ្នកប្រគល់ដីកាកោះ៥០០០៛ សរុបរួម៧០០០៛ ប្រាក់នេះ បានកាត់យកពី ប្រាក់៧០០០៛ ដែលដើមចោទបានបង់រួចហើយ ។

សាលក្រមនេះ ជំនុំជំរះជាសាធារណៈ ចំពោះមុខដើមចោទលោកឯក សុផល លោកលី អួង លោក ប្រ៊ុន អ៊ូ លោក នៅ ខឿន អ្នកស្រី គី ស៊ីង , លោក ញ៉ែត សុផាន់ និងចុងចម្លើយលោក មាស ហាន់

កំបាំងមុខដើមចោទលោក ទេព សាមឿន លោកសៀង ធឿន, លោកប៊ុន ជឿន លោក ស៊ីម ហូរ, លោក នួន ដារ៉ា និង អ៊ុង សួងអ៊ុយ បើកផ្ទះឧទ្ធរណ៍ ។

បានឃើញបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៣ ខែសីហា ឆ្នាំ១៩៩៤ របស់ឈ្មោះ ឯក សុផល តំណាងឱ្យដើមចោទទាំង១២នាក់ ដែលប្តឹងជំទាស់នឹងសេចក្តីសម្រេច របស់តុលាការក្រុងព្រះសីហនុនេះទាំងមូល ។

បានឃើញសាលដីការបៀបរដ្ឋប្បវេណីលេខ៦៩ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៥ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- បង្គាប់ឱ្យគូក្តី ជូនភស្តុតាងដោយរៀងៗខ្លួន បើសិនជាមាន ។

២- បង្គាប់ឱ្យធ្វើអង្កេតបំពេញបន្ថែម បើមានលេចហេតុថ្មី ។

៣- ចាត់ចៅក្រមប្រឹក្សាឱ្យចុះទៅពិនិត្យ ធ្វើអង្កេតស្រាវជ្រាវដល់ទីតាំងទំនាស់ ក្នុងករណីចាំបាច់បើមានគូក្តីស្នើសុំ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១២០ ចុះថ្ងៃទី២១ខែមីនា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- សម្រេចទទួលបណ្តឹងឧទ្ធរណ៍ប្រជាជន១២គ្រួសារ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែលើកចោលដោយទាស់ខុសនឹងគតិច្បាប់ ។

២- សម្រេចតម្កល់សាលក្រមតុលាការក្រុងព្រះសីហនុលេខ៤៥ ចុះថ្ងៃទី១២-០៨-៩៤ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដាន់សាលាឧទ្ធរណ៍ចំនួន១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង២៥៥៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយក្នុងកិច្ចប្រគល់ដីកាកោះ៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

៤-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុង កំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលេខ៨៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៦ របស់ឈ្មោះឯក សុផល តំណាងឱ្យប្រជាជន១១ គ្រួសារ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ១២០ ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ២៧៥ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៦ របស់តុលាការកំពូល សម្រេចចំពោះមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលបណ្តឹងសាទុក្ខលេខ៨៣ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ១៩៩៦ របស់លោកឯក សុផល តំណាងឱ្យប្រជាជន១១គ្រួសារ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២- ទុកជាមោឃៈ សាលដីការដ្ឋប្បវេណីលេខ១២០ ចុះថ្ងៃទី២១ ខែមីនាឆ្នាំ១៩៩៦ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣- បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១០៤ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៩៦ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤- រឹបអូសប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលចំនួន១៩.០០០រៀល ដែលឈ្មោះឯក សុផល បានបង់រួចហើយគឺ

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ .

- ចំណាយលើកិច្ចប្រគល់ដីកាកោះ ចំនួន១៥.០០០រៀល សរុប១៩០០០រៀល ហើយតម្រូវ ឱ្យឈ្មោះមាស ហាន់ តំណាងឱ្យរដ្ឋអំណាចខណ្ឌស្ទឹងហាវ សងប្រាក់១៩.០០០រៀល នេះ ទៅឱ្យឈ្មោះឯក សុផល វិញ ។

៥- សាលដីកានេះ ប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី២៩ ខែតុលា ឆ្នាំ១៩៩៦ ។

បានឃើញដីកាបញ្ជូនលេខ៥៤៨/៩៦ ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៩៦ របស់តុលាការក កំពូល ដែលត្រូវបានបង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១០៤ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៦ ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់ សាលាឧទ្ធរណ៍សម្រេចមុខគូក្តី ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ :

១- ទទួលជំនុំជំរះរឿងក្តីនេះ សារឡើងវិញ តាមអំណាចសាលដីកាលេខ២៧៥ ចុះថ្ងៃទី២៩-១០-៩៦ របស់ពូលាការកំពូល ។

២- តម្កល់សាលក្រមលេខ៤៥ ចុះថ្ងៃទី១២-០៨-៩៤ របស់តុលាការក្រុងព្រះសីហនុ ទុកជាបានការ តែកែប្រែចំណុចទី៣ និងទី ៤ ទៅជា

ក-ប្រគល់ដីទំហំ 114.332 m$^2$ ទៅឱ្យរដ្ឋអំណាចខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ គ្រប់គ្រងជាដីរដ្ឋ និងប្រើប្រាស់ជាប្រយោជន៍សាធារណៈ ចាប់ពីថ្ងៃដែលសាលដីកានេះចូលជាស្ថាពរ ។ តាមមាត្រា១ វាក្យខ័ណ្ឌ២ អនុក្រិត្យលេខ០៦ អនក្រ ចុះថ្ងៃទី០៦-០៥-៨៥ មាត្រា៥ និង៦៣ នៃច្បាប់ភូមិបាល។

ខ- ប្រជាពលរដ្ឋទាំងឡាយណា ដែលបានប្រើប្រាស់ប៉ះពាល់ដល់ដីខាងលើនេះ ត្រូវរុះរើសំណង់ និងសំភារៈ ចេញជាបន្ទាន់ ចាប់ពីថ្ងៃដែលសាលដីកានេះ ចូលជាស្ថាពរ ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន១៣០០០៛ ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយ ក្នុងនោះពន្ធចុះបញ្ជីនិង ពន្ធហ្នឹងចំនួន ២៥៥០ ៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន៤៥៛ រង្វាន់អ្នកប្រគល់ដីកាកោះ ចំនួន៥០០០៛ និងចំណាយលើអាជ្ញាធរតុលាការចំនួន ៥០០០៛ ។ នៅពេល

សាលដីកានេះ ចូលជាស្ថាពរ បង្គាប់ឱ្យដើមចោទទាំង១២គ្រួសារ បង់ពន្ធសមាមាត្រ១% លើតម្លៃដីទំនាស់ ។ ប្រាក់នេះដាក់ចូលថវិការដ្ឋ៨០% និងត្រូវបានវង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ % ។

៤- សាលដីកានេះ ជំនុំជំរះ ជាសាធារណៈ ចំពោះមុខគូក្តី បើកផ្លូវសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៤៧ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់លោកលី អួង តំណាងឱ្យប្រជាជន១២គ្រួសារ ដែលប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ៦៤ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសារណា ចុះថ្ងៃទី១៨-០៣-១៩៩៨ របស់ឈ្មោះលី អួង

បានឃើញសារណាតប ចុះថ្ងៃទី០២-០៤-១៩៩៨ របស់ឈ្មោះមាស ហាន់

- បានស្តាប់របាយករណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ ។

អាស្រ័យហេតុនេះ សូមក្រុមប្រឹក្សាជំនុំជំរះ មេត្តាពិចារណាតាមច្បាប់តទៅ ។

បានស្តាប់ចម្លើយរបស់ឈ្មោះលី អួង (តំណាងឱ្យ១២គ្រួសារ) ជាដើមចោទនិង ជាដើមបណ្តឹងសាទុក្ខនៅពេលជំនុំជំរះបានឆ្លើយថា បានជាខ្លួនប្តឹងមិនសុខចិត្ត ពីព្រោះដីនេះមិនមែនស្ថិតនៅ ក្នុងដីបំរុងរដ្ឋទេ គឺពិតជាដីរបស់ប្រជាជន១២គ្រួសារ ដែលគាត់បានកាន់កាប់ ចាប់តាំងពីឆ្នាំ១៩៨៥ រហូតមកដល់សព្វថ្ងៃនេះ ខ្លះមានបង្កាន់ដៃ ខ្លះក៏អត់មានបង្កាន់ដៃ ហើយបានដាដំណាំតូចធំ ដែលដំណាំទាំងនោះ មានអាយុជាង១០ឆ្នាំហើយ បើគិតមកដល់សព្វថ្ងៃនេះ។ សូមតុលាការមេត្តាជួយផ្តល់យុត្តិធមិឱ្យខ្លួនផង ។

បានស្តាប់ចម្លើយរបស់ឈ្មោះមាស ហាន់ ជាចុងចម្លើយ និងចុងម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជំរះបានឆ្លើយថា : រឿងដីទំនាស់នេះមានទំហំ 17O.3oo $m^2$ ជាដីបំរុងរដ្ឋ របស់ខណ្ឌស្ទឹងហាវ អាជ្ញាធរខណ្ឌ បានចេញសេចក្តីប្រកាសលេខ៩៣គប.ខសហ ចុះថ្ងៃទី២៩-០៦-៩១ គឺទុកដីនេះដើម្បីផលប្រយោជន៍ ជាសាធារណៈទូទៅក្នុងខណ្ឌ ។ ចំពោះទំហំដីពិតប្រាកដនោះ វាមានលក្ខណៈស្មុគ្រស្មាញ ការដែលសុរិយោដីគួរបញ្ជាក់ ដោយមានហត្ថលេខាខ្លួន នោះខ្លួនពុំបានដឹងទេ ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាបសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ.

# តុលាការកំពូល

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ៤៧ ចុះថ្ងៃទី២៤-០២-៩៨ របស់លោកលី អួង តំណាងឱ្យប្រជាជន១២ គ្រួសារ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះដល់ អង្គសេចក្ដីបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាព របស់សាលាជំរះក្ដី និងមាត្រា២២៦ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ ក៏ដូចតុលាការក្រុងព្រះសីហនុដែរ ដែលសម្រេចប្រគល់ដី 14.332m$^2$ ទៅឱ្យរដ្ឋអំណាចខណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុគ្រប់គ្រងជាដីរដ្ឋ និងប្រើប្រាស់ ជាប្រយោជន៍សាធារណៈ និងឱ្យប្រជាជនទាំងឡាយ ដែលប្រើប្រាស់ប៉ះពាល់ដល់ដីខាងលើនេះ រុះរើសំណង់ និងសម្អាតចេញ ដោយអាងហេតុថា ប្រជាជនទាំង១២គ្រួសារ ពុំអាចមានសិទ្ធិ កាន់កាប់ដីទំនាស់នេះទេ ដោយយោងតាមមាត្រា៦៣ នៃច្បាប់ភូមិបាល និងអនុលោមតាមមាត្រា១ វាក្យខ័ណ្ឌ២ នៃអនុក្រឹត្យលេខ០៦ អនក្រ ចុះថ្ងៃទី០៦-០៥-៨៥ និងមាត្រា៥ នៃច្បាប់ភូមិបាលនោះ ពុំទាន់មានភស្តុតាងធនល្មម ក្នុងការសម្រេចសេចក្ដីឡើយ ពីព្រោះថា

១- ការកំណត់អំពីទីតាំងដីទំនាស់ ពុំទាន់មានលក្ខណៈច្បាស់លាស់នៅឡើយ នៅក្នុងតំបន់ ដែលក្រុមប្រឹក្សារដ្ឋមន្ត្រីទុកជាតំបន់ឧស្សាហកម្ម ឬ ដីនោះ ជាអាងទឹកសាប ទីស្មសាន ឬថា ដីបំរុងសម្រាប់អភិវឌ្ឍរបស់ក្រុងដែរឬទេ ?

២- រឿងក្ដីនេះ មានដើមចោទចំនួន១២ នាក់ ដែលមានស្ថានភាព និងផលប្រយោជន៍ដោយឡែកៗពីគ្នា ។ ក្នុងការស៊ើបសួរនៅតុលាការក្រុងព្រះសីហនុ ក៏ដូចសាលាឧទ្ធរណ៍ដែរ តំណាងដើមចោទឆ្លើយការពារ តែផលប្រយោជន៍របស់ខ្លួនឯងប៉ុណ្ណោះ ដែលធ្វើឱ្យការស៊ើបសួរពុំមានលក្ខណៈច្បាស់លាស់អំពីសិទ្ធិរបស់ដើមចោទម្នាក់ៗឡើយ ។ កាលបរិច្ឆេទ នៃការកាន់កាប់ស្នាក់នៅ និងដំដំណាំរបស់ ដើមចោទម្នាក់ៗ មានលក្ខណៈដោយឡែកៗ ពីគ្នា ដែលគប្បីតុលាការពិចារណាតាមករណីដោយឡែក ។

៣-ភស្តុតាង នៃការអង្កេតរបស់តុលាការថ្នាក់ក្រោម មានការប្រែប្រួល និងផ្ទុយគ្នាដូចជា ចុងចម្លើយ និងសាក្សីចុងចម្លើយ សុទ្ធតែឆ្លើយថា ពេលចុះវាស់ដី ឃើញមានបិទដំណាំប្រជាជនខ្លះសំអាងនេះ ផ្ទុយគ្នា និងកំណត់ហេតុចុះថ្ងៃទី១២-០១-៩៨ ដែលថាដំណាំទាំងនោះមានអាយុយ៉ាងច្រើន៤ឆ្នាំ គឺដាំនៅឆ្នាំ១៩៩៤ ក្រោយការទទួលស្គាល់របស់លោកមាស ហាន់ ។

កំណត់ហេតុអង្កេតរបស់ចៅក្រមប្រឹក្សា សាលាឧទ្ធរណ៍ ក៏មានលក្ខណៈពុំឯកភាពគ្នាដែរ ៖

កំណត់ហេតុចុះថ្ងៃទី១៦-០៣-៩៦ថាទីតាំងទំនាស់គ្មានផ្ទះគ្មានប្រជាជនរស់នៅទេឯកំណត់ហេតុចុះថ្ងៃទី១៣-១១-៩៧ ថាបានជួបប្រពន្ធជ្រិន អ៊ី នៅទីនោះមានតូបចំចំការ មានដើមខ្នុរ ដែលម្ចាស់គេអះអាងថា ដាំនៅឆ្នាំ១៩៨៤ ។

៤- សេចក្តីប្រកាសលេខ៩៣ ចុះថ្ងៃទី២៩-០៦-៩១ ត្រូវបានកែតម្រូវនៅឆ្នាំ១៩៩២ ពីទទឹងដី ៣០០ម. មកទទឹងដី១៥០ម. ពេលវាស់វែង និងបោះបង្គោល ។ ក្នុងសេចក្តីប្រកាសនេះ ដីមានពីរកន្លែង គឺខាងស្តាំផ្លូវមានទទឹង៧០ម. ហើយខាងឆ្វេងមានទទឹង៣០០ម. ។ ចំណែកដីខាងស្តាំផ្លូវ ត្រូវបានចែកឱ្យអង្គភាពរដ្ឋ អង្គភាពទាំងនោះ បានចែកឱ្យបុគ្គលិក ហើយអ្នកខ្លះបានលក់បន្តទៀត ។ ហើយដីខាងឆ្វេងផ្លូវ ជាកម្មវត្ថុនៃដីទុកបំរុងរដ្ឋ ។

-យល់ឃើញថា ដោយពេលនេះ តុលាការកំពូលត្រូវសម្រេចដល់អង្គសេចក្តីនោះ តុលាការកំពូលគប្បីចាត់របៀបធ្វើការអង្កេតជាថ្មី ឱ្យបានច្បាស់លាស់ ។

**ហេតុដូច្នេះ**

**និច្ឆ័យសេចក្តីចំពោះមុខគូក្តី**

១- ចាត់របៀបឱ្យបំបែកសំណុំរឿងលេខ៧១ ចុះថ្ងៃទី១៦-០៣-៨៨ ជា១២សំណុំរឿង ដាច់ដោយឡែកពីគ្នា ។

២- ចាត់ឱ្យតុលាការក្រុងព្រះសីហនុ ធ្វើការស៊ើបអង្កេតជាថ្មី ដោយតម្រូវឱ្យដើមចោទម្នាក់ៗជូនសំអាង អំពីការកាន់កាប់ដីទំនាស់ដោយកំណត់ឱ្យច្បាស់ អំពីប្រវត្តិន៍នៃការកាន់កាប់នោះ ។

៣- ឱ្យអាជ្ញាធរក្រុងព្រះស៊ីហនុ បញ្ជាក់ឱ្យច្បាស់ថា ទីតាំងដីទំនាស់នេះ ស្ថិតក្នុងតំបន់ ឧស្សាហ៍កម្ម ដែលកំណត់ដោយក្រុមប្រឹក្សារដ្ឋមន្ត្រីឬទេ? ជាដីប្រភេទចំការ ឬ ជាដីសំរាប់សំណង់ ឬ ជាដី បំរុងសម្រាប់អាងទឹក ឬ ជាដីទីស្មសានឬទេ ?។

៤-ចាត់ឱ្យធ្វើអង្កេតបន្ថែមទៀត ក្នុងករណីចំបាច់ ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ១៩៩៩ ។